# ប្រវត្តិនិងសារប្រយោជន៍នៃទស្សនវិជ្ជា

ដោយ : បណ្ឌិត **ហែម ឡាច**
ប្រធានស្តីទីនាយកដ្ឋានទីតិសាស្ត្រ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

ទស្សនវិជ្ជាជាមុខវិជ្ជាមួយមានវ័យចំណាស់ មានកំណើតប្រហែល៦០០ឆ្នាំមុនគ្រិស្តសករាជ។ ទស្សនវិជ្ជាចាប់កំណើតតាំងពីពេលដែលមនុស្សចេះត្រិះរិះពិចារណារកហេតុផលចំពោះអ្វីៗដែលមាននៅក្នុងខ្លួនមនុស្ស និងចេះត្រិះរិះពិចារណាលើវត្ថុនិងបាតុភូតនៅក្នុងពិភពលោកនេះនិងក្នុងធម្មជាតិ។ គេបានដឹងថា ប្រទេសដែលចាប់ផ្តើមមានពន្លកទស្សនវិជ្ជាមុនគេ គឺប្រទេសឥណ្ឌា ចិន អេហ្ស៊ីប បាប៊ីឡូន ជាដើម។ ទស្សនវិជ្ជានៅប្រទេសទាំងអស់នោះបានចាប់កំណើតឡើងតែគ្រាន់តែជាពន្លកដំបូងប៉ុណ្ណោះពីព្រោះពុំទាន់មានប្រព័ន្ធច្បាស់លាស់នៅឡើយ។ ប៉ុន្តែប្រទេសដែលបានចងក្រងទស្សនវិជ្ជាជាប្រព័ន្ធ គឺប្រទេសក្រិកបុរាណសម័យ។ កាលនោះ ប្រទេសក្រិក គឺជាមហាអំណាចមួយដែលមានទំនាក់ទំនងទូលំទូលាយជាមួយប្រទេសជិតខាង និងប្រទេសផ្សេងៗទៀតក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេសនិងនយោបាយជាដើម។

បញ្ញវន្តក្រិក គឺជាពាណិជ្ជករធំៗ អាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរចំណេះដឹងទៅវិញទៅមកជាមួយបញ្ញវន្តនៃប្រទេសដទៃ និងមានសមត្ថភាពកសាងទស្សនវិជ្ជាជាប្រព័ន្ធ ដែលមានទ្រឹស្តីច្បាស់លាស់តាមទស្សនៈរៀងៗខ្លួន។ ទស្សនវិជ្ជាក្រិកបុរាណសម័យ ជាទស្សនវិជ្ជាដែលផ្អែកលើវិចារណញ្ញាណ។

## ១.កំណើតទស្សនវិជ្ជា

ទស្សនវិជ្ជា គឺជាការស្រឡាញ់គតិបណ្ឌិត ពោលគឺជាការសិក្សាជាប្រព័ន្ធអំពីបញ្ហាទូទៅនិងជាមូលដ្ឋាន ដូចជា ការសិក្សាអំពីអត្ថិភាព ហេតុផល ចំណេះដឹង តម្លៃ ចិត្ត និងភាសា។ ប្រភពខ្លះអះអាងថា ពាក្យទស្សនវិជ្ជានេះ ត្រូវបានបង្កើតឡើងដោយពីតាហ្គ័រ(Pythagore) (ប្រហែល៥៧០–៤៩៥ មុន គ.ស.) ទោះបីជាទ្រឹស្តីនេះត្រូវបានជំទាស់ដោយមនុស្សមួយចំនួនក៏ដោយ។ វិធីសាស្ត្រទស្សនវិជ្ជា រួមមាន ការសួរសំណួរ ការពិភាក្សាហ្មត់ចត់ ទឡ្ហីករណ៍សមហេតុផល និងការបង្ហាញជាប្រព័ន្ធ។

តាមប្រវត្តិសាស្ត្រ ទស្សនវិជ្ជាបានគ្របដណ្តប់គ្រប់ផ្នែកនៃចំណេះដឹង ហើយអ្នក

អនុវត្តត្រូវបានគេស្គាល់ថាជាទស្សនវិទូ។ «ទស្សនវិជ្ជាធម្មជាតិ» ដែលបានចាប់ផ្តើមជាមុខវិជ្ជាមួយនៅក្នុងប្រទេសឥណ្ឌាបុរាណ និងក្រិកបុរាណរួមបញ្ចូលផ្នែកតារាសាស្ត្រ ឱសថ និងរូបវិទ្យា។

ឧទាហរណ៍ ស្នាដៃរបស់អ៊ីសាក់ ញូតុន (Isaac Newton) ឆ្នាំ១៦៨៧ ដែលមានចំណងជើងថា «គោលការណ៍គណិតវិទ្យាស្តីអំពីទស្សនវិជ្ជាធម្មជាតិ» ក្រោយមក ត្រូវបានចាត់ថ្នាក់ជាសៀវភៅរូបវិទ្យា។ នៅសតវត្សរ៍ទី១៩ ការរីកចម្រើននៃសាកលវិទ្យាល័យស្រាវជ្រាវទំនើប បាននាំទៅដល់ការសិក្សាស្រាវជ្រាវទស្សនវិជ្ជា និងមុខវិជ្ជាផ្សេងៗទៀតនៃទស្សនវិជ្ជា ធ្វើវិជ្ជាជីវៈ និងជំនាញឯកទេស។ ចាប់តាំងពីពេលនោះមក វិស័យជាច្រើននៃការស៊ើបអង្កេតដែលជាផ្នែកប្រពៃណីនៃទស្សនវិជ្ជាបានក្លាយទៅជាមុខវិជ្ជាសិក្សាដាច់ដោយឡែក ជាពិសេស មុខវិជ្ជានានាដែលស្ថិតក្នុងវិទ្យាសាស្ត្រសង្គម ដូចជា ចិត្តវិទ្យា សង្គមវិទ្យា ភាសាវិទ្យា និងសេដ្ឋកិច្ច។

សព្វថ្ងៃនេះ មុខវិជ្ជាសំខាន់ៗនៃទស្សនវិជ្ជាដែលគេសិក្សាជាផ្លូវការរួមមាន ទី១ អស្តិរូបវិជ្ជា ដែលទាក់ទងនឹងលក្ខណៈជាមូលដ្ឋាននៃអត្ថិភាព និងតថភាព។ ទី២ ពុទ្ធិវិជ្ជា ដែលសិក្សាអំពីធម្មជាតិនៃចំណេះដឹងនិងជំនឿ។ ទី៣ សីលវិជ្ជា ដែលទាក់ទងនឹងតម្លៃសីលធម៌ និងទី៤ តក្កវិជ្ជាដែលសិក្សាអំពីវិធាននៃការពិចារណា ដែលអនុញ្ញាតឱ្យមនុស្សម្នាក់ៗទាញយកការសន្និដ្ឋានចេញពីមូលបដិញ្ញាពិត។ ទី៥ សោភណវិជ្ជាដែលទាក់ទងនឹងការសិក្សាអំពីបញ្ញត្តិសិល្បៈ សោភណភាព ការបង្កើតសិល្បៈ និងវាយតម្លៃសិល្បៈជាដើម។ ក្រៅពីនេះ នៅមានមុខវិជ្ជាសំខាន់ៗបន្តបន្ទាប់ទៀតរបស់ទស្សនវិជ្ជាដូចជា ទស្សនវិជ្ជាអំពីសាសនា ទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ ទស្សនវិជ្ជានយោបាយ ទស្សនវិជ្ជាអំពីភាសា និងទស្សនវិជ្ជាអំពីចិត្ត ជាដើម។

ទស្សនវិជ្ជាចាប់កំណើតនៅសតវត្សរ៍ទី៦មុនគ្រិស្តសករាជនៅទីក្រុងមីលេ(Milet) ដែលជារដ្ឋបុរីមួយនៅអាស៊ីមីនីរ(Asie Mineure) នៅមាត់សមុទ្រអេហ្សេ(Egee) ជាផ្នែកមួយនៃសមុទ្រមេឌីទែរ៉ានេ ស្ថិតនៅចន្លោះប្រទេសក្រិកនិងប្រទេសទួគី។ ទស្សនវិទូដំបូងដែលជាអ្នកបង្កើតទស្សនវិជ្ជា គឺតាឡែស(Thales) អាណាស៊ីម៉ង់(Anaximandre) និងអាណាស៊ីម៉ែន(Anaximene)។ ទស្សនវិទូទាំងបីរូបនេះ ជាសមាជិកនៃនិកាយមីលេ។ ប៉ុន្តែ ពេលនោះ ទស្សនវិទូទាំងបីរូបនេះ ពុំទាន់ដាក់ឈ្មោះពិតប្រាកដឱ្យទស្សនវិជ្ជាទេ។ បើតាមមតិរបស់ហេរ៉ាគ្លីត ឌុយប៉ុង(Heraclide du Pont) ស៊ីសេរ៉ុង(Ciseron) និង ឌីយ៉ូហ្សែនឡាអែរស៍(Diogene Laerce) អ្នកដាក់ឈ្មោះទស្សនវិជ្ជាពិតប្រាកដ គឺលោកពីតាហ្គ័រ(Pythagore)។

បន្ទាប់មក ទស្សនវិជ្ជាបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងបុរាណសម័យក្រិក ដូចជា

នៅក្នុងជំនាន់ប៉ារមេនីត(Parmenide)ហេរ៉ាគ្លីត (Heraclite) អេពីគួរ(Epicure) ពួកអេពីគួរ (Epicuriens) ពួកអត់ធ្មត់និយម និងពួកអាឡិចហ្សង់(Alexandrins)ជាដើម។

ទស្សនវិជ្ជាបានរីកពលដាលពេញបស្ចិមប្រទេស។ នៅពេលដែលបុរាណសម័យបញ្ចប់ទៅ មជ្ឈិមសម័យបានកើតឡើង។ អ្នកប្រាជ្ញបស្ចិមប្រទេស បានប្រៀបធៀបទស្សនវិជ្ជា ឬការគិតរបស់មនុស្សនៅក្នុងមជ្ឈិមសម័យថាជាការដេកលក់ឬជាការស្លាប់ពាក់កណ្តាល។ រេហ្ស៊ីន ពែរនូ(Regine Pernoud) បានសរសេរថា « រយៈពេលមួយពាន់ឆ្នាំនៃប្រវត្តិ សាស្ត្រមជ្ឈិមសម័យ គឺជាប្រវត្តិសាស្ត្រដែលស្ទើរតែលិតលង់ឬគួរឱ្យមើលងាយ »។ ទស្សនវិជ្ជាមជ្ឈិមសម័យ មុនដំបូង គឺជាសារលិខិតគ្រិស្តសាសនា ពោលគឺ មុខមាត់និងគំរូនៃជំនឿ និងគំនិតដែលដើរទៅរកភាពអាថ៌កំបាំងនៃព្រះយេស៊ូ ដោយសារជំនឿស៊ប់និងការស្រឡាញ់ បានប្តូរជំនួសឱ្យឧត្តមគតិនៃវិចារណភាពដែលធ្លាប់មានពីបុរាណសម័យទៅវិញ។ ទស្សនវិជ្ជាក្លាយជាមិត្តជិតស្និទ្ធរបស់ទេវវិជ្ជានិងចំណុះទេវវិជ្ជា។ ទស្សនវិទូសំខាន់ៗនៅក្នុងមជ្ឈិមសម័យគឺ សាំង អូហ្គុស្តាំង (Saint Augustin) សាំង អង់សែល(Saint Anselme) សាំង តូម៉ាសដាកាំង(Saint Thomas d'Aquin)។ ពួកគេបង្កើតនិកាយស្កូឡាស្ទីក(La Scolastique) ដែលសព្វថ្ងៃនេះ មានន័យបន្ទុះបង្អាប់ ពីព្រោះនិកាយនេះ បញ្ជាក់ពីការពិចារណាអរូបី ថាខ្វះការណ៍ពិត។

នៅបុនសម័យ ទស្សនវិជ្ជាខិតខំរើបម្រះចេញពីភាពលិតលង់នោះឡើងវិញ។ នៅពេលនោះ ការលើកតម្កើងមនុស្សនិយមមានកម្រិតខ្ពស់។ ទស្សនវិជ្ជាបុនសម័យ គឺជាទស្សនវិជ្ជាមនុស្សនិយមដែលមានន័យទូលាយ គឺដោយសារវិធីជាក់ស្តែងនិងសរុបសម្រាប់ស្រាវជ្រាវអំពីមនុស្ស។ ទស្សនវិទូសំខាន់ៗនៅសម័យនោះ រួមមាន នីកូឡាម៉ាឈៀវ៉ែល(Nicolas Machiavel) តូម៉ាស ម៉រ (Thomas More) អេជែន ដឺឡាប៉ូអេទី('Etienne de la Bo'etie) មីសែល ដឺម៉ុងតែញ(Michel de Montaigne) ហ្សកដាណូ ប្រ៊ុយណូ(Giordano Bruno) ហ្វ្រង់ស៊ី បាកុង(Francis Bacon)។ ប៉ុន្តែការកៀបសង្កត់ពីអំណាចសាសនា នៅតែមាននៅឡើយ។ ប្រ៊ុយណូ ត្រូវបានដុតទាំងរស់ដោយសារគាត់អះអាងថា«ផែនដីមានរាងមូល និងផែនដីវិល»។

ទស្សនវិជ្ជាបានរីកចម្រើនម្តងទៀតនៅសតវត្សរ៍ទី១៧។ ទស្សនវិទូសំខាន់ៗនៅក្នុងសម័យកាលនោះ គឺ ដេកាត(Descartes) ស្ពីណូហ្សា(Spinoza) ម៉ាឡឺប្រង់(Malebranche) ឡៃបនីស(Leibniz)។ ចាប់ពីសតវត្សរ៍ទី១៨មក ទស្សនវិទូធំៗបានបញ្ចេញទស្សនៈផ្សេងៗគួរឱ្យកត់សម្គាល់។ កូពែរនិក(Copernic) អ៊ីម៉ានុយអែល ខាន់(Immanuel Kant) ដេវីដ ហ៊ូម (David Hume) យ៉ូហាន់ ហ្គុតលីប ហ្វិធទ័រ

(Johann Gottlieb Fichte) សែលលិង (Shelling) ហេហ្គែល(Hegel) កាល់ ម៉ាក(Marx) អង់ហ្គែល (Engels) លេនីន(L′enine) នីតឆេ(Nietzche) បើកសិន(Bergson) ហសសើល(Husserl) ហៃដឺហ្គ័រ(Heidegger) វីយ៉ែន(Vienne) វីតហ្គិនស្តាញ (Vittgenstein) រ៉ាស្សែល(Russell) ស៊ីហ្គមិន ហ្វ្រីដ (Sigmund Freud) សុទ្ធសឹងបន្សល់ទុកវណ្ណកម្មពិសេសៗសម្រាប់ការពិចារណារបស់មនុស្ស។

ទស្សនៈផ្សេងៗរបស់ទស្សនវិទូទាំងឡាយបានបែងចែកជាប្រព័ន្ធទស្សនវិជ្ជាផ្សេងៗ ដូចជា រូបធាតុនិយម មនោនិយម ទ្វិកនិយម វិជ្ជមាននិយម មនុស្សនិយម អត្ថិភាពនិយម ម៉ាក្សនិយម កំណត់និយម រចនាសម្ព័ន្ធនិយម វាសនានិយម ។ល។ រីឯតួអង្គទស្សនវិជ្ជាវិញ វាកាន់តែបែកចេញជាច្រើនផ្នែកថែមទៀត ដូចជា ទស្សនវិជ្ជាអំពីសកម្មភាព ទស្សនវិជ្ជាអំពីស្មារតី ទស្សនវិជ្ជាអំពីប្រវត្តិសាស្ត្រ ទស្សនវិជ្ជាអំពីច្បាប់ ទស្សនវិជ្ជាអំពីសិល្បៈ ទស្សនវិជ្ជាសីលធម៌។ល។

ការរៀបរាប់ទាំងអស់ខាងលើគឺជាប្រវត្តិទាក់ទងនឹងទស្សនវិជ្ជាបស្ចិមប្រទេស។ ចំណែកទស្សនវិជ្ជាបូព៌ាប្រទេសក៏មានប្រវត្តិរបស់ខ្លួនដែរ។ ខាងក្រោមនេះ គឺជាការរៀបរាប់ដោយសង្ខេបអំពីទស្សនវិជ្ជាបូព៌ាប្រទេស ឬទស្សនវិជ្ជាអាស៊ី។

ទស្សនវិជ្ជាបូព៌ាប្រទេស មានលក្ខណៈទូលំទូលាយ ដែលចាប់ផ្តើមតាំងពី ៥,000 ឆ្នាំកន្លងមក។ ទស្សនវិជ្ជាបូព៌ាប្រទេស ក៏ជាទស្សនវិជ្ជាដ៏ស្មុគ្រស្មាញ និងពេញនិយមបំផុតនៅលើភពផែនដីនេះដែរ ដោយមានមនុស្សជាច្រើនប្រកាន់ខ្ជាប់នូវទស្សនវិជ្ជាសាសនានេះដែលមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ។

ទស្សនវិជ្ជាបូព៌ាឬទស្សនវិជ្ជាអាស៊ីរួមមាន ទស្សនវិជ្ជាផ្សេងៗដែលមានដើមកំណើតនៅអាស៊ីបូព៌ានិងខាងត្បូង រួមទាំងទស្សនវិជ្ជាចិន ទស្សនវិជ្ជាជប៉ុន ទស្សនវិជ្ជាកូរ៉េ ជាដើម ដែលលេចធ្លោនៅអាស៊ីបូព៌ា និងទស្សនវិជ្ជាឥណ្ឌា (រួមទាំងទស្សនវិជ្ជាហិណ្ឌូ ទស្សនវិជ្ជាជេន ទស្សនវិជ្ជាពុទ្ធសាសនា) ដែលលេចធ្លោនៅអាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ ទីបេ និងម៉ុងហ្គោលី។

អ្វីដែលយើងបានឃើញ គឺគ្រាន់តែអ្វីមួយដែលគេរៀបរាប់តាមប្រភពដែលមានភ័ស្តុតាងជាក់ស្តែងប៉ុណ្ណោះ។ តាមពិត ប្រជាជាតិនីមួយៗ សុទ្ធតែមានគំនិតឬទ្រឹស្តីទស្សនវិជ្ជារៀងៗគ្រាន់តែថាតើពួកគេបានបន្សល់ទុកវាដែរឬអត់ប៉ុណ្ណោះ។ លើសពីនេះទៀត តើទស្សនវិជ្ជាទាំងនោះមានឥទ្ធិពលខ្លាំងលើប្រទេសជិតខាង ប្រទេសក្នុងតំបន់ និងពិភពលោកដែរឬទេ? បើវាមាន នោះវាត្រូវបានគេស្គាល់កាន់តែច្បាស់ ប៉ុន្តែបើវាមិនមានទេ នោះវានឹងមិនត្រូវបានគេស្គាល់ឡើយ។

ការរៀបរាប់ដោយសង្ខេបពីឈ្មោះទ្រឹស្តី និងឈ្មោះទស្សនវិជ្ជាទាំងនេះ គ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃទស្សនវិជ្ជាទាំងមូល

ព្រោះនៅមានទ្រឹស្ដីនិងតួអង្គទស្សនវិជ្ជាជាច្រើនទៀតដែលមិនបានលើកយកមកបង្ហាញនៅទីនេះ។

នៅប្រទេសជឿនលឿន ទស្សនវិទូខិតខំស្រាវជ្រាវនិងបញ្ចេញទស្សនៈជ្រៅជ្រះដើម្បីជាវិភាគទានដល់ស្មារតីរបស់មនុស្ស។ ទង្វើនោះគឺជាការបង្ហាត់បង្រៀនឱ្យស្មារតីចេះធ្វើសកម្មភាពស៊ីជម្រៅនិងយល់កាន់តែច្បាស់អំពីជីវិត វត្ថុ និងបាតុភូតនានា។ នៅប្រទេសអន់ថយមួយចំនួនហាក់ដូចជាមានការព្រងើយកន្តើយចំពោះមុខទស្សនវិជ្ជា។ ហេតុអ្វីបានជាមានការព្រងើយកន្តើយបែបនេះ? តើការបណ្ដោយឱ្យស្មារតីដេកលក់បែបនេះនឹងផ្ដល់ផលវិបាកអ្វីខ្លះ?

នៅប្រទេសកម្ពុជាយើង ទស្សនវិជ្ជាបានលេចត្រដែតឡើងចាប់ពីសម័យហ្វូណនសម័យចេនឡា ជាពិសេស សម័យអង្គរ។ ទស្សនវិជ្ជាត្រូវបានបង្កប់នៅក្នុងសិលាចារឹកនានាដែលបញ្ជាក់ឱ្យឃើញថាខ្មែរមានទស្សនៈជ្រៅជ្រះរបស់ខ្លួនដើម្បីរួមចំណែកកសាងនិងការពារមាតុភូមិ។ បទចម្រៀង «សារ៉ាវ៉ាន់ខ្មែរ» ក៏បានលើកយកពាក្យទស្សនវិជ្ជាមកគូសបញ្ជាក់ថា ខ្មែររុងរឿងដោយខ្មែរមានទស្សនវិជ្ជានិងវិស័យជាច្រើនទៀត។ ប៉ុន្តែ នៅពេលដែលខ្មែរបែកបាក់គ្នា និងមានការឈ្លានពានពីសត្រូវគ្រប់ទិសទី ខ្មែរបានកសាងទស្សនវិជ្ជារបស់ខ្លួនមានលក្ខណៈទុទិដ្ឋិនិយមហួសហេតុផ្អែកលើជំនឿកម្មផលងងឹតងងល់ ផ្អែកលើព្រេងវាសនាជាធំ និងផ្អែកលើកម្មពៀរពីអតីតជាតិ។ ចំណែកឯប្រព័ន្ធទស្សនវិជ្ជាជ្រៅជ្រះមានលក្ខណៈតស៊ូប្រយុទ្ធនឹងសត្រូវត្រូវបានបំផ្លាញចោលឬលួចយកចេញទៅក្រៅ។ គេមានជំនឿងងឹតងងល់ ខ្វះការពិចារណារកហេតុផលដែលនាំឱ្យខ្មែរបាត់បង់ទឹកដី ទ្រព្យធនរបស់ជាតិ។

គ្រោះថ្នាក់ម៉្យាងទៀតដែលធ្លាក់មកលើពលរដ្ឋខ្មែរ គឺការមិនស្រឡាញ់ទស្សនវិជ្ជា មិនព្រមសិក្សាទស្សនវិជ្ជា រហូតដល់យល់ថាទស្សនវិជ្ជាមានលក្ខណៈអរូបីហួសហេតុ ពិបាកយល់ ពិបាកសិក្សា ហើយក៏បោះបង់ចោលមុខវិជ្ជានេះទៅ។ ការបោះបង់ចោលទស្សនវិជ្ជាហាក់បីដូចជាការសម្លាប់ស្មារតីពលរដ្ឋខ្មែរ។ កម្មវិធីសិក្សាដែលខ្វះមុខវិជ្ជាទស្សនវិជ្ជា ជាកម្មវិធីសិក្សាមួយដែលខ្វះការគិតហ្មត់ចត់ ខ្វះទស្សនវិជ្ជាសីលធម៌ ដែលជាមុខវិជ្ជាដ៏សំខាន់ក្នុងការរួមចំណែកកសាងសីលចរិតរបស់មនុស្ស។ ការបោះបង់ចោលទស្សនវិជ្ជា គឺជាការលុបចោលសំណួរ «ហេតុអ្វី» អំពីហេតុផល និងទំនាក់ទំនងរវាងហេតុនិងផល។ ការបោះបង់ចោលសំណួរហេតុអ្វីមានន័យថាមិនឆ្ងល់ មិនសង្ស័យអំពីសច្ចភាព។

[1] ឆយ យីហ៊ាង៖ រៀនធ្វើទស្សនវិជ្ជា គ.ស. ២០០៦

*ហ្សាក់គីលីន រុស (Jacqueline Russ) បញ្ជាក់ថា «ចំពោះយើង ការលុបចោលទាំងស្រុងនូវសំណួរថាហេតុអ្វី ហាក់ដូចជាធ្វើឱ្យស្មារតីមនុស្សគ្មានហេតុផល»។*

*មនុស្សទាំងអស់គ្នាកំពុងរស់នៅក្នុងពិភពលោកមួយ ដែលមានការវិវឌ្ឍប្រែប្រួលយ៉ាងខ្លាំង។ វាមានទាំងការរីកចម្រើនថ្កុំថ្កើង និងហានិភ័យផ្សេងៗ។ ពិភពលោកបច្ចុប្បន្ននេះជួបប្រទះនឹងបញ្ហាប្រឈមធំៗ ដូចជា គ្រោះអត់ឃ្លាន ការបះបោរ អំពើភេរវកម្ម ការប្រែប្រួលបរិស្ថាន ជាដើម។ មនុស្សមួយចំនួនអាចរស់នៅជាមួយបញ្ហា ឬការរំខាននេះបាន ចំណែកឯមនុស្សមួយចំនួនទៀតមិនអាចរស់នៅបានទេ។ ដូច្នេះ មនុស្សគិតពិចារណាពិភាក្សា ស្វែងរកដំណោះស្រាយសម្រាប់ជីវិតរស់នៅរបស់ខ្លួន គ្រួសាររបស់ខ្លួន សង្គមរបស់ខ្លួនគេ និងពិភពលោកទាំងមូល។*

## ២.អត្ថន័យនៃទស្សនវិជ្ជា

*ទស្សនវិជ្ជាមានអត្ថន័យច្រើនយ៉ាង ដោយផ្អែកទៅលើការយល់ឃើញរបស់ទស្សនវិទូម្នាក់ៗ។ អ្នកដែលបង្កើតពាក្យ Philosophia គឺ ពីតាហ្គ័រ (Pythagore)។ Philosophia មកពីពាក្យ Philia និងពាក្យ Sophia។ Philia មានន័យថា សេចក្តីស្នេហា ហើយ Sophia មានន័យថា គតិវិញ្ញូ។ ហេតុនេះ Philosophia មានន័យថា សេចក្តីស្នេហាចំពោះគតិវិញ្ញូ។ គតិវិញ្ញូ គឺជាគតិរបស់វិញ្ញូ។ នៅក្រិកបុរាណសម័យ គេឱ្យតម្លៃវិញ្ញូថាជាជនដែលមានពុទ្ធិសាកល ទូលំទូលាយ ចេះសព្វមុខវិជ្ជា មានការប៉ិនប្រសប់ មានសមត្ថភាពបរិបូរណ៍ និងមានសុភនិច្ឆ័យលើគ្រប់កិច្ចការទាំងពួង ជាជនដែលប្រកបដោយចរិយាសម្បត្តិ និងគុណធម៌ល្អប្រពៃ មានប្រាជ្ញាមោះមុត ធ្វើអ្វីត្រឹមត្រូវតាមវិចារណញ្ញាណ និងមានបទពិសោធយ៉ាងជ្រៅជ្រះ។*

***អារីស្តូត*** *(Aristote) ជាទស្សនវិទូក្រិកដ៏ល្បីល្បាញ បានឱ្យនិយមន័យទស្សនវិជ្ជាថា «ជាការគិតដែលមានគោលបំណងខ្ពស់បំផុតទាក់ទងទៅនឹងសច្ចភាពនៃបទពិសោធដែលមានតម្លៃទាំងឡាយ»។ អារីស្តូតយល់ថា គោលបំណងរបស់ទស្សនវិជ្ជា គឺស្វែងរកទំនាក់ទំនងនៃបទពិសោធទាំងអស់យ៉ាងជិតដល់ និងយ៉ាងទូលំទូលាយតាមដែលអាចធ្វើទៅបាន។*

***ប៊ីតថល*** *(Bittle) បានឱ្យនិយមន័យទស្សនវិជ្ជាថា «ជាវិទ្យាសាស្ត្រស្តីពីភាវៈនានានៅក្នុងបុព្វហេតុ និងគោលការណ៍ចុងក្រោយបំផុតទាំងឡាយ ដែលបានមកពីជំនួយនៃវិចារណញ្ញាណរបស់មនុស្សតែមួយគត់»។ ទស្សនវិជ្ជាគឺជាវិទ្យាសាស្ត្រ ពីព្រោះវាផ្អែកទៅលើពុទ្ធិ គឺមិនមែនគ្រាន់តែផ្អែកលើមតិយោបល់ ទ្រឹស្តី ឬសម្មតិកម្មនោះទេ។ វាជាវិទ្យាសាស្ត្រមួយស្តីពីភាវៈនានា ពីព្រោះវាគ្របដណ្តប់លើអ្វីៗទាំងអស់ ដែលអាចយល់បានដោយគំនិតរបស់របស់មនុស្ស ពោលគឺ មាន*

ន័យថាអ្វីៗដែលមានអត្ថិភាព អ្វីដែលនឹងមានអត្ថិភាពដែលគេអាចគិតពិចារណាបានឬអាចយល់ដឹងបាន។

ទោះបីជាពាក្យទស្សនវិជ្ជានេះមានអត្ថន័យច្រើនយោងតាមសម័យកាល និងតាមទស្សនវិទូម្នាក់ៗ ប៉ុន្តែអត្ថន័យជាមូលដ្ឋាននៃពាក្យទស្សនវិជ្ជា គឺការស្រឡាញ់គតិបណ្ឌិត ពុទ្ធិឬគតិវិញ្ញូ។

ក្រៅពីនេះទស្សនវិជ្ជាក៏ជាមុខវិជ្ជាសិក្សាមួយដ៏ទូលំទូលាយនិងជ្រៅជ្រះផងដែរ។

**ធីថឹស** (Titus) និងលោក **ស្មីត** (Smith) បានផ្តល់ឱ្យនូវទស្សនៈប្រាំយ៉ាងស្តីអំពីទស្សនវិជ្ជា ដែលបំពេញបន្ថែមគ្នាទៅវិញទៅមកដូចខាងក្រោម៖

-ឥរិយាបថផ្ទាល់ខ្លួនចំពោះជីវិត និងចក្រវាល។

-វិធីនៃការគិតបែបឆ្លុះបញ្ចាំង និងការអង្កេតប្រកបដោយវិចារណញ្ញាណ។

-ការប៉ុនប៉ងដើម្បីទទួលបាននូវទស្សនៈរួមមួយ។

-ការវិភាគភាសាតាមបែបតក្កវិជ្ជានិងគូសបញ្ជាក់ពីអត្ថន័យនៃពាក្យនិងបញ្ញត្តិ។

-ជាបណ្តុំនៃបញ្ហាក៏ដូចជាទ្រឹស្តីស្តីអំពីដំណោះស្រាយបញ្ហាទាំងអស់នោះដែរ។

ហ្ស៊ូល ឡាស៊ីលីយ៉េ (Jules Lachelier) សរសេរថា «ទស្សនវិជ្ជាមិនមែនជាមុខវិជ្ជាដែលមានពុទ្ធិសម្រាប់ធ្វើជារូបមន្តនោះទេ»។ អ្នកសិក្សាត្រូវចងចាំគំនិតនិងទ្រឹស្តីខ្លះរបស់ទស្សនវិទូ។ ប៉ុន្តែអ្នកមិនត្រូវទទួលយកទាំងស្រុងនូវគំនិតទាំងនោះដោយងងឹតងងល់ទេ។ គាត់គូសបញ្ជាក់ថា គ្មានប្រព័ន្ធទស្សនវិជ្ជាណាមួយដែលមានទស្សនៈស្របគ្នាទាំងស្រុងឡើយ។ សាំង ថូម៉ាស ដាកាំងលើកតម្កើងគ្រិស្តសាសនា រីឯ កាល់ ម៉ាក្ស ថាគ្រប់សាសនាគឺជាអាភៀនសម្រាប់បំពុលប្រជាជន។ ប្លាតុង យល់ថា ព្រលឹងមានលក្ខណៈអមតៈ មិនស្លាប់តាមរាងកាយ ប៉ុន្តែ អារីស្តូតយល់ថា នៅពេលដែលរាងកាយស្លាប់ នោះព្រលឹងក៏ស្លាប់ដែរ។ តូម៉ាស់ ហូប យល់ថាមនុស្សមានធម្មជាតិឃោរឃៅពីកំណើត ចំណែករូស្សូ យល់ថា មនុស្សមានធម្មជាតិល្អពីកំណើត តែសង្គមវិញទេដែលធ្វើឱ្យមនុស្សពុករលួយ។

ហ្ស៊ូល ឡាស៊ីលីយ៉េ ពោលបន្ថែមទៀតថា ប្រសិនបើអ្នករង់ចាំរៀនទស្សនវិជ្ជាដែលមានពុទ្ធិត្រឹមត្រូវច្បាស់លាស់ឥតខ្ចោះ អ្នកពិតជាអស់សង្ឃឹមយ៉ាងខ្លាំង។ ទស្សនវិជ្ជាស្នើឱ្យអ្នកសិក្សាមានសិល្បៈក្នុងការរស់នៅនិងមានសីលធម៌ក្នុងខ្លួន។ ប៉ុន្តែ ទស្សនវិជ្ជាដែលស្នើឱ្យមនុស្សមានចរិយាត្រឹមត្រូវ ក៏មានលក្ខណៈផ្សេងៗគ្នាដែរ។ នៅក្នុងទស្សនវិជ្ជា គឺគ្មានសច្ចភាពតាមលំដាប់លំដោយដូចទ្រឹស្តីបទគណិតវិទ្យាឬដូចច្បាប់រូបវិទ្យាឡើយ។ នៅក្នុងប្រវត្តិវិទ្យា ប្រព័ន្ធទ្រឹស្តីត្រូវបន្តដោយ

ប្រព័ន្ធទ្រឹស្តីមួយទៀត។ រីឯនៅក្នុងទស្សនវិជ្ជាវិញ ទស្សនវិទូម្នាក់ៗច្រើនតែប្រើប្រាស់ទ្រឹស្តីរបស់ខ្លួនដើម្បីបដិសេធឬទទួលយកទ្រឹស្តីរបស់ទស្សនវិទូផ្សេងទៀត។

ហ្គាស់ដហ្វ (M. Gusdorf) ពោលថា «គ្មានទស្សនវិជ្ជាណាមួយដែលអាចបញ្ចប់ទស្សនវិជ្ជាបានទេ ទោះបីជាទស្សនវិជ្ជានោះមានបំណងបកស្រាយការណ៍អាថ៌កំបាំងនៃគ្រប់ទស្សនវិជ្ជាក៏ដោយ»។ ប្រជាជនអាល្លឺម៉ង់និយាយថា ទស្សនវិទូប្រៀបដូចជាសិល្បករដែលក្នុងនោះមានវិចិត្រករ តន្ត្រីករ និងកវីពោលគឺ ម្នាក់ៗសុទ្ធតែមានវិធីសង្កេតពិភពលោកផ្ទាល់របស់គាត់។ យើងត្រូវយល់ថាទ្រឹស្តីទស្សនវិជ្ជាទាំងឡាយមានតម្លៃខ្ពង់ខ្ពស់ដោយសារឧទាហរណ៍ដែលទស្សនវិជ្ជានោះផ្តល់ឱ្យ។ នោះជាឧទាហរណ៍ដែលទស្សនវិទូនានាខំលើកបញ្ជាក់យ៉ាងម៉ឺងម៉ាត់។

អ៊ីម៉ានុយអែល ខាន់ (Emmanuel Kant) ពោលថា «គ្មានទស្សនវិជ្ជាណាមួយដែលគេអាចរៀនសូត្រតាមបានទាំងស្រុងនោះទេ គេគ្រាន់តែអាចរៀនធ្វើឬបង្កើតទស្សនវិជ្ជាប៉ុណ្ណោះ» ។ បើតាមសម្តីនេះ សូម្បីតែទស្សនវិជ្ជារបស់គាត់ ក៏គាត់មិនអះអាងថាជារូបមន្តដែរ។ បើរៀនតាមទស្សនវិជ្ជាព្រះពុទ្ធ យើងគ្រាន់តែយល់ពីទស្សនវិជ្ជាមួយឬគ្រាន់តែយល់ជ្រុងមួយនៃពិភពទស្សនវិជ្ជាប៉ុណ្ណោះ។ ហេតុនេះ យើងគួរតែសិក្សាពីទស្សនវិជ្ជាអ៊ិស្លាមសាសនា ទស្សនវិជ្ជាគ្រិស្តសាសនា ទស្សនវិជ្ជាព្រហ្មញ្ញសាសនា ទស្សនវិជ្ជារបស់ទស្សនវិទូម្នាក់ៗនៅបូព៌ាប្រទេស បស្ចិមប្រទេស ជាដើម។ ទង្វើបែបនេះ មានន័យថាបើកទូលាយពុទ្ធិទស្សនវិជ្ជា ដោយជៀសវាងការធ្លាក់ចូលទៅក្នុងគម្ពីរនិយមស្ងាប់ក្រឡា។ គម្ពីរនិយមស្ងាប់ក្រឡាគឺជាការនិយមអនុវត្តតាមគម្ពីរ ទស្សនវិជ្ជាឬទ្រឹស្តីណាមួយដោយងងឹតងងល់និងខ្វះការពិចារណា។[2]

## ៣.ការផ្តាច់ខ្លួនរបស់វិទ្យាសាស្ត្រមួយចំនួនចេញពីទស្សនវិជ្ជា

ពីបុរាណ ទស្សនវិជ្ជាក្តោបមុខវិជ្ជាសំខាន់ៗជាច្រើន ដោយគេចាត់ទុកវាជាចំណេះដឹងសកល។ ជាក់ស្តែង ស្នាដៃដ៏មានឥទ្ធិពលជាច្រើនលើវិស័យផ្សេងៗគ្នារបស់អារីស្តូតបានបន្តជះឥទ្ធិពលយ៉ាងជ្រាលជ្រៅដល់អ្នកគិតក្រោយៗមកទៀតចាប់ពីទស្សនវិជ្ជាវិទ្យាសាស្ត្រ រហូតដល់សិល្បៈនិងនយោបាយ។ ប៉ុន្តែនៅពេលដែលវិធីវិទ្យាសាស្ត្រនានាកាន់តែទទួលបានជោគជ័យក្នុងការបង្កើតពុទ្ធិជាក់ស្តែង មានភាពជាក់លាក់ និងអាចផ្ទៀងផ្ទាត់បាន នោះមុខវិជ្ជាខ្លះដែលសព្វថ្ងៃយើងស្គាល់ថាជាវិទ្យាសាស្ត្រនោះក៏ចាប់ផ្តើមបែកចេញពីទស្សនវិជ្ជាម្តងមួយៗជាបន្តបន្ទាប់៖

[2] ឆយ យីហ៊ាង៖ រៀនធ្វើទស្សនវិជ្ជា ជ.ឯ.ម.

-គណិតវិទ្យា និងតារាវិទ្យា (astronomie) ត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី៣មុន គ.ស. ដោយ អឺគ្លីត (Euclide)។

-រូបវិទ្យាត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី១៧ ដោយ ញូតុន (Newton)។

-គីមីវិទ្យាត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី១៨ ដោយ ឡាវ៉ស្យេ(Lavoisier)។

-ជីវវិទ្យាត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី១៩ដោយក្លូតប៊ែណា (Claude Bernard)។

-ចិត្តវិទ្យាត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី១៩ ដោយ រីបូ(Ribot)។

-សង្គមវិទ្យាត្រូវបានបំបែកចេញពីទស្សនវិជ្ជានៅសតវត្សរ៍ទី១៩ ដោយ អូគុសកុង (Auguste Comte) និង ឌួខិម (Durkheim)។

ប៉ុន្តែ គួរកត់សម្គាល់ថា ការចាត់ទុកទស្សនវិជ្ជាថាជាចំណេះដឹងសកលឬជាវិទ្យាសាស្ត្រនៃវិទ្យាសាស្ត្រនៅតែមានជាហូរហែរហូតមកទល់ពេលនេះ។ នៅសតវត្សរ៍ទី១៧ ស្នាដៃរបស់ដេកាត(Descartes) ទាក់ទងសឹងតែលើគ្រប់មុខវិជ្ជាផ្នែកវិទ្យាសាស្ត្រ។ ស្នាដៃរបស់ ញូតុន ដែលជាសំណេរវិទ្យាសាស្ត្រសុទ្ធសាធក៏មានឈ្មោះថា«ទស្សនវិជ្ជាធម្មជាតិ» ដែរ ហើយរហូតមកដល់ចុងសតវត្សរ៍ទី១៩ ពាក្យទស្សនវិជ្ជានៅមានន័យជាវិទ្យាសាស្ត្រនៅឡើយ ហើយមានអ្នកប្រាជ្ញឬទស្សនវិទូច្រើនណាស់ដែលមានចំណេះដឹងច្រើនមុខស្ទើរតែអាចចាត់ទុកបានថាជាចំណេះដឹងសកល។ ឧទាហរណ៍ អំពែ (Ampère)ជាគណិតវិទូផង ជារូបវិទូផង ចិត្តវិទូផង និងទស្សនវិទូផងដែរ។ រីឯ ពង់ការ៉េ (Poincaré) វិញគឺជាគណិតវិទូផង រូបវិទូផង និងទស្សនវិទូវិទ្យាសាស្ត្រផងដែរ។

បើទោះបីជាវិទ្យាសាស្ត្រទាំងនោះបែកចេញពីទស្សនវិជ្ជាក៏ដោយ ក៏វិទ្យាសាស្ត្រទាំងនោះនៅតែត្រូវការទស្សនវិជ្ជាសម្រាប់ការស្រាវជ្រាវ ការវិភាគ និងការកំណត់សច្ចភាពក្នុងវិស័យរបស់ខ្លួនដែរ។ ចំណែកទស្សនវិជ្ជាវិញ ក៏នៅតែបន្តតាមដានការវិវឌ្ឍនៃវិទ្យាសាស្ត្រទាំងនោះ ដោយពិនិត្យមើលយ៉ាងហ្មត់ចត់អំពីការកំណត់ទឡ្ហីករណ៍ ដែលក្នុងនោះវាពិនិត្យតាមដានយ៉ាងប្រុងប្រយ័ត្នលើការបង្ហាញសេចក្តីថ្លែងឬមូលបដិញ្ញានីមួយៗក្នុងការគាំទ្រសន្និដ្ឋានរបស់ខ្លួនដើម្បីឱ្យប្រាកដថា ពួកវាមានភ័ស្តុតាងគ្រប់គ្រាន់ រឹងមាំ សមហេតុផលអាចយកជាការបាន និងគ្មានវិរុទ្ធនិទស្សន៍ ដែលនឹងនាំទៅដល់ការសន្និដ្ឋានមួយត្រឹមត្រូវស្របនឹងសច្ចភាព។ លើសពីនេះទៀត ទស្សនវិជ្ជាក៏នៅតែព្យាយាមតម្រង់ទិសវិទ្យាសាស្ត្រទាំងអស់ឱ្យវិវឌ្ឍទៅតាមផ្លូវត្រឹមត្រូវ ដោយឈរលើ

ហេតុផលនិងគោលបំណងត្រឹមត្រូវប្រកបដោយសីលធម៌សម្រាប់បម្រើមនុស្សជាតិជាជាងគ្រាន់តែបំពេញមហិច្ឆិតារបស់ខ្លួន។

## ៤.វិធីទស្សនវិជ្ជាក្រិកបុរាណសម័យ

ទស្សនវិជ្ជា ខុសពីវិទ្យាសាស្ត្រពិសោធន៍ ដោយទស្សនវិជ្ជាពឹងផ្អែកច្រើនលើការត្រិះរិះពិចារណា ហេតុផល និង ទឡ្ហីកម្មជាជាងការពិសោធឬការសង្កេត។ ហេតុនេះ ទស្សនវិជ្ជាដែលបានកើតឡើងតាំងពីសតវត្សរ៍ទី ៦ មុនគ្រិស្តសករាជមក គឺមានវិធីរបស់ខ្លួនដើម្បីស្វែងរកសច្ចភាពនិងគតិបណ្ឌិត។ ជាងនេះទៀត វិធីទស្សនវិជ្ជាគឺជាមូលដ្ឋានដ៏សំខាន់នៃវិធីវិទ្យាសាស្ត្រដទៃទៀត។

### ៤.១-តើវិធីទស្សនវិជ្ជាជាអ្វី?

វិធីទស្សនវិជ្ជាសំដៅដល់មធ្យោបាយ បច្ចេកទេស ឬវិធីសាស្ត្រទាំងឡាយណាដែលទស្សនវិទូប្រើដើម្បីវិភាគ និងសិក្សាស្វែងយល់អំពីបញ្ហាចម្បងៗ ដូចជា តថភាព ពុទ្ធិ តម្លៃ អត្ថិភាព ហេតុផល គំនិត និងភាសា។ វិធីទស្សនវិជ្ជាមានលក្ខណៈជាការគិតបែបឆ្លុះបញ្ចាំង ដើម្បីស្វែងរកសច្ចភាពនិងគតិបណ្ឌិត ពិនិត្យផ្ទៀងផ្ទាត់លើបញ្ញត្តិផ្សេងៗ ពង្រីកពុទ្ធិ និងស្វែងយល់បញ្ហាផ្សេងៗរបស់ទស្សនវិជ្ជា ដូចជា សីលធម៌ អស្តិរូបវិជ្ជា ពុទ្ធិវិជ្ជា និង តក្កវិជ្ជា។

វិធីទស្សនវិជ្ជាមិនមែនសម្រាប់តែទស្សនវិទូឬអ្នកប្រាជ្ញទេ តែមនុស្សទូទៅសុទ្ធតែបានប្រើវិធីទស្សនវិជ្ជានៅក្នុងជីវិតប្រចាំថ្ងៃ គ្រាន់តែគេពុំបានចាប់អារម្មណ៍ប៉ុណ្ណោះ។ ការប្រើវិធីទស្សនវិជ្ជា មិនចាំបាច់ទាមទារឱ្យមនុស្សនោះមានសមត្ថភាពពិសេសអស្ចារ្យ ឬក៏ត្រូវហ្វឹកហាត់ហ្មត់ចត់ស៊ីជម្រៅក្នុងរយៈពេលយូរឡើយ។ មនុស្សបានប្រើវិធីទស្សនវិជ្ជា ហើយបានអភិវឌ្ឍវិធីទាំងនោះជាបន្តបន្ទាប់នៅក្នុងការពិចារណាដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់ខ្លួន។

ទោះជាយ៉ាងណា ការប្រើវិធីទស្សនវិជ្ជាក៏មានកម្រិតទៅតាមគោលបំណងនិងចំណោទបញ្ហាដែលអ្នកប្រើប្រាស់ជួបប្រទះដែរ។ ជាក់ស្តែង មនុស្សទូទៅជួបប្រទះបញ្ហាក្នុងជីវិតប្រចាំថ្ងៃ ពួកគេត្រូវពិចារណាស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ។ ដោយឡែក ទស្សនវិទូដែលត្រូវស្វែងរកសច្ចភាពដែលមានលក្ខណៈសាកល គឺត្រូវប្រើវិធីទស្សនវិជ្ជាជាក់លាក់ ស៊ីជម្រៅ និងប្រកបដោយវិចារណញ្ញាណជាង។

ទស្សនវិជ្ជាមានវិធីជាច្រើនដើម្បីស្វែងរកសច្ចភាពនិងគតិបណ្ឌិត។ ប៉ុន្តែ នៅនេះ យើងលើកមកតែវិធីទស្សនវិជ្ជាមួយចំនួននៅក្រិកបុរាណសម័យសម្រាប់ការយល់ដឹងជាមូលដ្ឋានប៉ុណ្ណោះ ព្រោះជាសម័យកាលនិងជាទីកកើតឡើងនូវទស្សនវិជ្ជាជាប្រព័ន្ធដែលមានឥទ្ធិពលយ៉ាងធំធេងនៅលើសកលលោក។

## ៤.២-វិធីសូក្រាត

សូក្រាត (Socrate ៤៦៩-៣៩៩ មុន គ.ស.) ជាទស្សនវិទូក្រិកបុរាណសម័យដ៏ល្បីល្បាញ។ នៅមុនជំនាន់សូក្រាត ទស្សនវិជ្ជាផ្ដោតការសិក្សាលើប្រភពដើមនិងធម្មជាតិរបស់ពិភពលោក ហើយវិធីទស្សនវិជ្ជាគឺការសង្កេតធម្មជាតិផ្ទាល់ ពិចារណាដោយប្រើគំនិតអរូបីធ្វើទូទៅនីយកម្មដើម្បីពន្យល់បកស្រាយ។ ដោយឡែក ទស្សនវិជ្ជារបស់សូក្រាតបានងាកមកផ្ដោតលើមនុស្ស សីលធម៌ ចំណេះដឹងអត្ថិភាព និងរដ្ឋាភិបាល។ សូក្រាតបានប្រើវិធីសួរ-ឆ្លើយដើម្បីស្វែងរកសច្ចភាព និងផ្ដល់ពុទ្ធិថ្មីៗដល់យុវជន។

វិធីរបស់សូក្រាតមានពីរសំខាន់ គឺ វិធីចំអក និង វិធីសម្រាលៈ

-វិធីចំអក: ការចោទសួរធ្វើឱ្យគូសន្ទនាឈានទៅក្នុងទំនាស់នៅក្នុងខ្លួនដោយការលែងប្រាកដប្រជាលើចំណេះដឹងរបស់ខ្លួន គិតមិនចេញ ឆ្លើយមិនរួច ហើយស្គាល់ភាពល្ងង់ខ្លៅរបស់ខ្លួននិងទទួលស្គាល់សច្ចភាព។

-វិធីសម្រាល: ការធ្វើឱ្យសច្ចភាពលេចធ្លោឡើង ធ្វើឱ្យគូសន្ទនាយល់ព្រមថាត្រឹមត្រូវ ហើយតាមរយៈវិធីនេះ លោកបានផ្ដល់ពុទ្ធិដល់គូសន្ទនា។

វិធីសូក្រាតនេះអាចប្រៀបធៀបថា ជាការស្ដារទឹកល្អក់កករនៅបាតពាងឱ្យអស់ ហើយចាក់ទឹកថ្មីល្អចូលបំពេញពាងវិញ។

ជាមួយនេះ ទស្សនវិជ្ជារបស់សូក្រាតក៏បានប្រើវិធីនិយមន័យដែរ។ វិធីនិយមន័យជាវិធីទស្សនវិជ្ជាមួយក្នុងការស្វែងយល់បញ្ញត្តិមួយតាមរយៈការបង្កើតគំរូនិយមន័យច្បាស់លាស់ ជាក់លាក់ និងសំខាន់ ដោយការវិភាគ ចោទសួរ និងការកែលម្អ។ ក្រោយមកទស្សនវិទូប្លាតុង និងទស្សនវិទូអារីស្តូត បានប្រើវិធីនិយមន័យនេះយ៉ាងស៊ីជម្រៅនិងយ៉ាងទូលំទូលាយថែមទៀត។

## ៤.៣-វិធីប្លាតុង

ប្លាតុង(Platon ៤២៨-៣៤៧ មុនគ.ស.) ជាសិស្សរបស់ទស្សនវិទូសូក្រាត និងជាទស្សនវិទូក្រិកបុរាណសម័យដ៏ល្បីល្បាញ។ គេបានសិក្សាយល់ដឹងអំពីទស្សនវិជ្ជារបស់សូក្រាតភាគច្រើនតាមកំណត់ត្រារបស់លោក។

ដើម្បីបង្ហាញទស្សនវិជ្ជារបស់ខ្លួន ប្លាតុងបានប្រើវិធីបដិសំយោគ ដែលជាទម្រង់នៃការសន្ទនា។ ការសន្ទនារបស់ប្លាតុងមិនមែនគ្រាន់តែជាការកត់ត្រានូវអ្វីដែលសូក្រាតបាននិយាយនោះទេ តែជាឧបករណ៍ទស្សនវិជ្ជាមួយសម្រាប់ស្វែងយល់ការណ៍ពិត។ តាមរយៈការផ្លាស់ប្ដូរយោបល់ គូសន្ទនាទាំងឡាយត្រូវបានជំរុញឱ្យប្រើការគិតពិចារណាកាន់តែស៊ីជម្រៅ និងស្វែងរកនិយមន័យ ឬការយល់ដឹងដែលច្បាស់លាស់ជាងមុន។ ប្លាតុងបានប្រើកិច្ចសន្ទនាដើម្បីបង្ហាញនិងអភិវឌ្ឍទ្រឹស្ដីទស្សនវិជ្ជាផ្ទាល់ខ្លួន

របស់លោកជាពិសេសទ្រឹស្តីអំពីទម្រង់ឬគំនិត ពោលគឺមានតែគំនិតទេនាំទៅរកពុទ្ធិសច្ចៈ។

### ៤.៤- វិធីអារីស្តូត

*អារីស្តូត* (Aristote ៣៨៤ - ៣២២ មុន គ.ស.) ជាទស្សនវិទូក្រិកបុរាណសម័យដ៏ល្បីល្បាញ ដែលមានទស្សនវិជ្ជាយ៉ាងស៊ីជម្រៅ។ អារីស្តូតជាសិស្សរបស់ប្លាតុង តែលោកមានវិធីទស្សនវិជ្ជាផ្ទាល់ខ្លួនរបស់លោក។ លោកជាអ្នកបង្កើតប្រព័ន្ធតក្កវិជ្ជាដំបូងគេបំផុត ដែលគេហៅថា តក្កសាស្រ្ត ( syllogism ) ។ វិធីទស្សនវិជ្ជារបស់អារីស្តូតមានប្រព័ន្ធច្បាស់លាស់ មានលក្ខណៈវិទ្យាសាស្រ្ត និងមានលក្ខណៈពិសោធន៍។ គេបានចាត់ទុកលោកជាបិតាតក្កវិជ្ជា និងវិទ្យាសាស្រ្តជាច្រើន។

វិធីទស្សនវិជ្ជាសំខាន់ៗរបស់អារីស្តូតមានការអង្កេតពិសោធន៍ និងវិធីអនុមានញែកៈ

-ការអង្កេតពិសោធន៍ ជាវិធីនៃការយល់ដឹងអំពីធម្មជាតិ និងពិភពជាក់ស្តែងជុំវិញខ្លួន តាមរយៈការអង្កេតផ្ទាល់ ពោលគឺការអង្កេតពិភពធម្មជាតិនិងពិភពជាក់ស្តែងជាមូលដ្ឋាននៃការគិតពិចារណារកពុទ្ធិ។

-វិធីអនុមានញែក ជាវិធីទស្សនវិជ្ជាមួយដែលពិចារណាពីការប្រើគោលការណ៍រួមឬច្បាប់ទូទៅដើម្បីទាញទៅរកជាសន្និដ្ឋានដោយឡែក។

## ៥.សារប្រយោជន៍នៃទស្សនវិជ្ជា

នៅក្នុងកម្មវិធីសិក្សាជាច្រើន គេតម្រូវឱ្យមានការសិក្សាទស្សនវិជ្ជា។ តាមពិតទស្សនវិជ្ជាគឺជាផ្នែកមួយដ៏សំខាន់នៃការអប់រំបែបសេរីរបស់និស្សិត។ ប្រការនេះបញ្ជាក់អំពីការទទួលស្គាល់នូវសារប្រយោជន៍នៃការសិក្សាទស្សនវិជ្ជានៅក្នុងការអភិវឌ្ឍបុគ្គលម្នាក់ៗ និងនៅក្នុងការត្រៀមខ្លួនដើម្បីជ្រើសរើសមុខវិជ្ជាជីវៈរបស់គេ។

លោក ***ពីតាហ្គ័រ*** (Pythagore) គឺជាមនុស្សបានផ្តល់ចម្លើយដំបូងបំផុតចំពោះសំណួរថា ហេតុអ្វីបានជាយើងត្រូវសិក្សាទស្សនវិជ្ជា។ លោកពោលថា ទស្សនវិជ្ជា គឺជាការស្វែងរកពុទ្ធិសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។ ការសិក្សាទស្សនវិជ្ជាមិនមែនគ្រាន់តែផ្តល់ឱ្យយើងនូវពុទ្ធិបន្ថែមប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវការយល់ដឹងកាន់តែទូលំទូលាយនិងស៊ីជម្រៅទៀតផង។ ម្យ៉ាងទៀត ទស្សនវិជ្ជាជួយឱ្យអ្នកសិក្សាយល់ដឹងពីខ្លួនឯងកាន់តែច្បាស់លាស់ឡើង យល់ដឹងពីអ្នកដទៃ យល់ដឹងពីពិភពលោកពិត និងយល់ដឹងពីអត្ថន័យនៃជីវិត។ ពោលគឺការយល់ដឹងដែលអាចរីកចម្រើនឥតឈប់ឈរ។ ការយល់ដឹងបែបនេះ នឹងធ្វើឱ្យគេទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងយ៉ាងសុខដុមជាមួយនឹងមនុស្សទាំងឡាយផ្សេងទៀត ជួយបង្កលក្ខណៈងាយស្រួលឱ្យគេសម្របសម្រួល

ជាមួយនឹងបរិស្ថានរបស់ខ្លួន ហើយនិងធ្វើឱ្យជីវិតរបស់ខ្លួនកាន់តែមានន័យ។

នៅក្នុងការសិក្សាទស្សនវិជ្ជា អ្នកសិក្សានឹងត្រូវបានគេបង្ហាញឱ្យឃើញពីទស្សនវិជ្ជានានារបស់អ្នកប្រាជ្ញផ្សេងៗ។ ផ្តើមចេញពីគំនិតរបស់អ្នកគិតទាំងនោះ អ្នកសិក្សាអាចអភិវឌ្ឍទស្សនវិជ្ជាផ្ទាល់ខ្លួន ដែលនឹងផ្តល់នូវទិសដៅចាំបាច់ដល់ជីវិតរបស់គេ។ មនុស្សមិនអាចបន្តរស់នៅដោយគ្មានទិសដៅ ឬ គោលបំណងបានឡើយ។ ទស្សនវិជ្ជានឹងជួយយើងក្នុងការកំណត់គោលដៅនានាដែលយើងនឹង កំណត់សម្រាប់ជីវិតដោយឡែកៗរបស់យើង។

ចុងក្រោយ ទស្សនវិជ្ជានឹងផ្តល់ឱ្យអ្នកសិក្សានូវមូលដ្ឋានដ៏រឹងមាំនៅក្នុងការឆ្លើយតបនឹងសេចក្តីត្រូវការនៃវិជ្ជាជីវៈរបស់ខ្លួននិងក្នុងការប្រឈមមុខនឹងបញ្ហាផ្សេងៗនៃជីវិត។ ទស្សនវិជ្ជាក៏នឹងដឹកនាំមនុស្សឱ្យធ្វើការសម្រេចចិត្តសំខាន់ៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយផ្តើមចេញពីទស្សនវិស័យដ៏ទូលំទូលាយ ពីព្រោះទស្សនវិជ្ជាធ្វើឱ្យមនុស្សមានទស្សនៈរួមស្តីពីបទពិសោធន៍របស់គេនិងជីវិតផ្ទាល់ខ្លួនរបស់គេ។

តម្លៃផ្សេងទៀតជាច្រើន គេអាចទទួលបានមកពីការសិក្សាទស្សនវិជ្ជា។ លើសពីនេះទៅទៀត ប្រសិនបើគេព្យាយាមយល់ដឹងពីធម្មជាតិនិងការប្រតិបត្តិនានានៃវិស័យខុសៗគ្នា វាជះឥទ្ធិពលទៅលើជីវិតមនុស្ស។

យោងទៅតាមលោក **ខាញ** (Cahn) មនុស្សប្រកបដោយគតិបណ្ឌិត គឺជាអ្នកដែលមានការយល់ដឹងទស្សនវិជ្ជា។ មនុស្សបែបនេះ មិនអាចត្រូវបានគេបំភ័យតាមរយៈអំណះអំណាងបែបមានៈ ឬបែបសិទ្ធាន្តនិយមបានឡើយ ហើយគេត្រៀមតស៊ូប្រឆាំងទៅនឹងអ្នកដែលត្រួតត្រាគំនិតរបស់គេ។ ដូច្នេះ ការសិក្សាទស្សនវិជ្ជាអាចផ្តល់ជាកំផែងការពារប្រឆាំងនឹងទាសភាពខាងគំនិត និងផ្តល់នូវគំរូមួយដែលយើងអាចគិតនិងធ្វើអំពើប្រកបដោយបញ្ញា។[3]

ទោះបីជាយ៉ាងណាក៏ដោយ ក៏មានមនុស្សមួយចំនួននិយាយមើលងាយ បន្ទុចនិងមិនចូលចិត្តទស្សនវិជ្ជា ពីព្រោះតែហេតុផលនេះ ឬហេតុផលនោះ។ មនុស្សខ្លះទៀតបាននិយាយថា ទស្សនវិជ្ជាគ្រាន់តែជាការលេងសម្តីឬគំនិតតែប៉ុណ្ណោះ។

ខាងក្រោមនេះគឺជាមូលហេតុបួនយ៉ាង ដែលគេតែងតែលើកឡើងដើម្បីវិនិច្ឆ័យពីទស្សនវិជ្ជា៖

-ទស្សនវិជ្ជាពិបាកយល់។

-ទស្សនវិជ្ជាមានលក្ខណៈសាំញ៉ាំ មិនអាច អនុវត្តបានឬមិនទាក់ទងទៅនឹងតថភាព។

[3] Steven M. Cahn, *A New Introductory to Philosophy*. New York: Harper and Row publishers, 1971, p. 12.

-គ្មានការរីកចម្រើននៅក្នុងវិស័យទស្សនវិជ្ជាទេ ពីព្រោះសូម្បីតែទស្សនវិទូទាំងឡាយ ក៏មានគំនិតខុសៗគ្នាឬប្រឆាំងនឹងគ្នាដែរ។

-ទស្សនវិជ្ជាតែងតែយកគោលការណ៍ជាមូលដ្ឋានមករិះគន់ វាធ្វើឱ្យគ្រោះថ្នាក់ឬប៉ះពាល់ដល់បុគ្គលនិងសង្គម។

-ទស្សនៈអវិជ្ជមានទាំងនេះ គឺផ្អែកទៅលើហេតុផលដែលកើតមកពីការភាន់ច្រឡំឬការយល់ដឹងមិនពេញលេញអំពីទស្សនវិជ្ជា។ ជាការពិត ទស្សនវិជ្ជាមានសារប្រយោជន៍ច្រើនណាស់ចំពោះអ្នកសិក្សា។ ទស្សនវិជ្ជាជួយឱ្យយើងមានការត្រិះរិះពិចារណាស៊ីជម្រៅនិងធ្វើការសម្រេចចិត្តប្រកបដោយគតិបណ្ឌិតហើយអាចជួយឱ្យមនុស្សមានសីលធម៌ សង្គមមានសណ្តាប់ធ្នាប់ សុខដុមរមនានិងមានការអភិវឌ្ឍ។

**សម្រង់គំនិតទស្សនវិជ្ជា**

***សូក្រាត*** ( Socrate) «ជីវិតដែលគ្មានការត្រួតពិនិត្យ គឺជាជីវិតដែលគ្មានតម្លៃក្នុងការរស់នៅ»។

***ប្រៃមែន*** ( Brightman) «ទស្សនវិជ្ជា គឺជាមគ្គុទ្ទេសក៍នៃជីវិត»។

*អារីស្តូត* ( Aristote) «សុភមង្គល គឺជាសកម្មភាពដែលអនុលោមទៅតាមគុណធម៌។ កុសលរបស់មនុស្សបង្កើតជាសកម្មភាពខាងស្មារតីដែលអនុលោមទៅតាមគុណធម៌ ហើយប្រសិនបើមានគុណធម៌ច្រើនជាងមួយ គួរអនុលោមតាមគុណធម៌ពិតប្រាកដនិងល្អបំផុត។»

**ឯកសារពិគ្រោះ**


១-ឆយ យីហ៊ាង៖ រៀនធ្វើទស្សនវិជ្ជា គ. ស. ២០០៦

២-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

៣-ទស្សនវិជ្ជាថ្នាក់ទីបញ្ចប់ ខេមរយានកម្ម ភ្នំពេញ ១៩៧៤

៤-Alfrido Panizo, Ethics or Moral Philosophy,1964, Manila.

៥-Felix M, Montemayor, Ethics The Philosophy of life,1994,Philipine.

៦-Mariano Artigas,Introduction to Philosophy,1984,Sinag Publishers ,Inc,Manila.

៧-Venancio B. Ardales, Introduction Text to Philosophy,1987, New York,